

# អេពីគួរ

## Epicure

" រូបធាតុនិយម គ្មានអាទិទេព "



## L'Épicurism (341-270BC)

- សាលាទស្សនវិជ្ជារបស់ អេពីគួរ ជាកន្លែងបង្រៀនមនុស្សឱ្យចេះធ្វើដំណើរទៅរកសុភមង្គល។ ជាក់ស្តែងនៅលើខ្លោងទ្វារចូលសាលា គេឃើញមានផ្លាកធំមួយសរសេរថា: *អ្នកទេសចរណ៍ទាំងឡាយ! នេះជាកន្លែងល្អប្រសើររបស់មិត្ត! សុភមង្គល ឧត្តុង្គ ឧត្តមនៅទីនេះ គឺ សេចក្តីសប្បាយរីករាយ។*
- អេពីគួរ ចែកការសិក្សាទស្សនវិជ្ជារបស់ខ្លួនជាបីគឺ៖
  1. គម្ពីរ Canon : សិក្សាពីទ្រឹស្តីពុទ្ធិ
  2. រូបវិទ្យា Physcics : សិក្សាពីធម្មជាតិ
  3. សីលវិជ្ជា Ethics : សិក្សាពីឥរិយាបថមនុស្សនាំទៅរកសុភមង្គល

## L'Épicurism (341-270BC)

- អេពីគួរ បានសន្មតថា ព្រលឹងគឺគ្មានអ្វីក្រៅតែធាតុម្យ៉ាងស្តើងហើយស្រាលដែលមានពាសពេញនៅក្នុងខ្លួនយើង ហើយមានឋាន:ជាអវ:យវ:របស់យើងផងដែរប្រហែលគ្នានឹងដៃជើង ឬក៏ក្បាលរបស់យើង។
- ដូច្នេះហើយ គាត់សន្និដ្ឋានថា៖ កាលណាអង្គកាយរបស់យើងស្លាប់ ព្រលឹងក៏ត្រូវស្លាប់ជាមួយគ្នាដែរ។ នៅពេលនោះព្រលឹងនឹងត្រូវរលាយបាត់ដូចផ្សែងទឹក ហើយក៏គ្មានមនោសញ្ចេតនាអ្វីបន្តិចបន្តួចសោះនៅក្នុងខ្លួនរបស់យើង។ ដូចនេះ សេចក្តីស្លាប់មិនមែនជារបស់មួយដ៏អាក្រក់សាមាន្យនោះទេ។



## L’Épicurism (341-270BC)

- ទស្សនវិជ្ជារបស់ អេពីគួរ ផ្ទុយស្រឡះពីទស្សនវិទូ សេណុង បិតានៃលទ្ធិ **Stoicism** ។
- មេរៀនទាំងឡាយរបស់ អេពីគួរ មានលក្ខណៈផ្ទុយទាំងស្រុងពីទស្សនវិជ្ជារបស់ "***អត់ធ្មត់និយម***" ឬ **Stoicism** ។
- **Stoicism** ឱ្យយើងសុខចិត្តទទួលយកការឈឺចាប់គ្រប់បែបយ៉ាង ព្រោះជាការកំណត់របស់ធម្មជាតិ។
- អេពីគួរ វិញ លោកឱ្យចៀសចេញឆ្ងាយពីការឈឺចាប់ ហើយស្វែងរកការសប្បាយ។



## L'Épicurism (341-270BC)

- តាមទស្សនៈរបស់ អេពីគួរ ធម្មជាតិរីកលូតលាស់តាមក្រិតក្រមរបស់ខ្លួនឯងផ្ទាល់ ពុំមានអន្តរាគមន៍ពីអាទិទេពឡើយ។ ចំណែកច្បាប់ និងរដ្ឋវិញកើតមានឡើង មិនមែនតាមរយៈធម្មជាតិដែរ គឺមិនមែនកើតចេញពីធម្មជាតិទេ តែជាលទ្ធផលដែលកើតមកពីការកំណត់ និងការឯកភាពគ្នារបស់មនុស្ស។
- អេពីគួរ បញ្ជាក់ថា យុត្តិធម៌ មិនដែលមានអត្ថិភាពដោយខ្លួនឯងឡើយ។ យុត្តិធម៌ ជាកិច្ចព្រមព្រៀងថានឹងមិនបង្ករផលអាក្រក់ដាក់គ្នាទៅវិញទៅមក។ ហើយយុត្តិធម៌នេះ កើតមានទំនាក់ទំនង រវាងមនុស្ស និងមនុស្ស ក្នុងតំបន់ណាមួយជាក់លាក់។

## L’Épicurism (341-270BC)

- លោកបញ្ជាក់ថា យុត្តិធម៌ មានលក្ខណៈខុសៗគ្នា វាអាស្រ័យទៅនឹងច្បាប់នៃបណ្តារដ្ឋខុសៗគ្នានោះ។ បានន័យថា បើមានការកំនត់ថា យុត្តិធម៌សម្រាប់តំបន់ណាមួយ ក្នុងលំហរណាមួយ នោះគេមិនអាចនិយាយថា នេះជាយុត្តិធម៌សម្រាប់ទីតាំងផ្សេងៗទៀតបានឡើយ។ ការពិតក្នុងតំបន់ពីរខុសគ្នា យុត្តិធម៌មិនដូចគ្នាទេ។

- ពាក់ព័ន្ធនឹងបញ្ហាច្បាប់ លោកបានបដិសេធចោលទាំងស្រុងនូវអត្ថិភាពនៃច្បាប់ធម្មជាតិ។ អេពីគួរ មិនជឿថា ច្បាប់ធម្មជាតិជាអ្នកបង្កើតច្បាប់សង្គមឡើយ។



## L'Épicurism (341-270BC)

ដែលមានផលអាក្រក់លើគ្នាទៅវិញទៅមក ប៉ុន្តែត្រូវខំប្រឹងទប់ស្កាត់។

- លោកថា សន្តិសុខបច្ចុប្បន្ននេះកើតមានឡើងដោយសារជីវភាពរស់នៅមានសភាពស្ងប់ស្ងាត់ និងអវត្តមានភាពរញ៉េរញ៉ៃ។
- បញ្ហានយោបាយ ជាលទ្ធផលនៃការចរចារវាងមនុស្ស និងមនុស្ស អំពីផលប្រយោជន៍រួម និងសុវត្ថិភាពរបស់ពួកគេ។
- អេពីគួរ ឱ្យនិយមន័យសង្គមថា ជាសម្ព័ន្ធបុគ្គលទាំងឡាយ។ នៅពេលធ្វើសកម្មភាពសង្គមបុគ្គលត្រូវតែសម្របសម្រួលទៅតាម

## L'Épicurism (341-270BC)

- គ្រាន់តែរន្ទះ យើងចាត់ទុកថាជាកំហឹងរបស់ព្រះភ្លាមមួយរំពេច។
- អេពីគួរ ប្រាប់ថា ការចេះដឹងវិទ្យាសាស្រ្ត អាចបំបាត់កង្វល់ដ៏គ្មានមូលដ្ឋាននេះ ហើយនាំមនុស្សទៅរកភាពស្ងប់បានក្នុងផ្លូវចិត្ត។
- អេពីគួរ បានយកទស្សនវិជ្ជា រូបធាតុនិយម របស់ ដេម៉ូគ្រីត មកធ្វើជាមូលដ្ឋាន ដើម្បីបញ្ជាក់ពីរឿងហេតុទាំងឡាយដែលកើតមាននៅក្នុងធម្មជាតិ។
- អេពីគួរ ពន្យល់ពីបាតុភូតផ្សេងៗដូចជា សូរ្យគ្រាស និងហេតុផលពិតប្រាកដ ដែលបណ្តាលឱ្យមានជំងឺប៉េស្តជាដើម។



# L'Épicurism (341-270BC)

- តាមសេចក្តីពិត តាំងពីយើងបានកើតមកនៅលើផែនដីនេះ... គឺជាការធម្មតាពេកណាស់ដែលយើងតែងតែចង់រស់នៅដោយទាញយកសេចក្តីសុខសប្បាយឱ្យបានច្រើនជាទីបំផុត។ ក៏ប៉ុន្តែគេមិនត្រូវចចេសចង់នៅទីនេះទៀតទេ ក៏ដូចមនុស្សម្នាក់ដែលបានបរិភោគឆ្ងាញ់រួចហើយ ក៏មិនត្រូវចចេសចង់អង្គុយនៅកន្លែងតុម្ហូបតទៅទៀតដែរ។
- អេពីគួរ ពោលថា មនុស្សយើងដោយភាគតិចណាស់ដែលចេះទាញយកផលប្រយោជន៍ពីជីវិត។ មនុស្សគ្រប់ៗគ្នាតែងតែមើលស្រាលចំពោះស្ថានភាពបច្ចុប្បន្នដែលគេកំពុងរស់នៅ។

## L'Épicurism (341-270BC)

- សេរីភាព របស់មនុស្ស ជាទំនួលខុសត្រូវរបស់គេ ចំពោះការជ្រើសរើសអ្វីមួយប្រកបដោយវិចារណញ្ញាណ សម្រាប់ធ្វើជាគំរូជីវិតរបស់ពួកគេ។ ដែនសីមានៃសេរីភាពរបស់មនុស្ស ជាដែនសីមានៃទំនួលខុសត្រូវរបស់ពួកគេចំពោះខ្លួនគេ។
- សុភមង្គលមនុស្ស តាមអេពីគួរ ជាអ្វីម្យ៉ាងដែលអវត្តមានការឈឺចាប់។ ដើម្បីទទួលបានសុភមង្គល អេពីគួរបានសំណូមពរឱ្យមនុស្សយើងដកខ្លួនឱ្យចេញផុតពីកិច្ចការសង្គម។ ទស្សនៈរបស់អេពីគួរ ពោរពេញទៅដោយភាពព្រងើយកន្តើយចំពោះបញ្ហានយោបាយ និងការបំផុសមិនឱ្យមានការចូលរួមយ៉ាងសកម្មនៅ



## L'Épicurism (341-270BC)

ប្រភពដើមនៃគ្រប់អង្គកាយទាំងអស់...។ ពេលអ្វីៗទាំងអស់នៅក្នុងធម្មជាតិគឺត្រូវបានសាងសង់ឡើងដោយប្រព័ន្ធនៃអាតូម។

- ក្រៅពីអាតូម អេពីគួរបានសន្មតថា មានវត្ថុមាននៃរបស់មួយទៀតដែលគេហៅថា លំហ ។ តាមពិតលំហពុំមែនជាវត្ថុធាតុដើម ហើយក៏ពុំមែនជាប្រព័ន្ធនៃអង្គកាយនានានោះឡើយ។ អេពីគួរគ្រាន់តែចាត់ទុកថា លំហ ជាប្រភពដើមនៃចលនាតែប៉ុណ្ណោះឯង គឺដោយហេតុថា៖ បើគ្មានលំហតូចៗ ឬសភាពឃ្លាតគ្នារវាងអង្គកាយ និងអង្គកាយ នៅរាយហៃពាសពេញក្នុងធម្មជាតិនោះទេ វាក៏គ្មានអ្វីមួយដែលអាចរើបម្រាស់ ឬក៏អាចបង្កើតជាចលនា។

## L’Épicurism (341-270BC)

- អេពីគួរ បដិសេធគំនិតថា មានព្រះអាទិទេពជ្រៀតជ្រែកកិច្ចការមនុស្ស។
- ចំពោះអ្នកដែលអះអាងថា៖ មានអាទិទេពមួយដែលមានការស្រឡាញ់ពេញចិត្ត ចេះដឹងសព្វគ្រប់ និងមានអំណាចគ្រប់យ៉ាង... អេពីគួរ បានតវ៉ាថា តើព្រះមានឆន្ទៈការពារអំពើបាបឬ? ឬមួយក៏មិនអាចការពារបាន? បើអីចឹងគាត់គ្មានកម្លាំងមហិមាទេ តែបើគាត់អាចការពារបាន តែគ្មានឆន្ទៈនោះគឺគាត់អាក្រក់ តែបើគាត់អាចការពារបាន ព្រមទាំងមានឆន្ទៈទៀត...តើអំពើអាក្រក់កើតមានម្ដេចកើតទៅ?

## L’Épicurism (341-270BC)

- អេពីគួរ បង្ហាញថា ចំណេះដឹង គឺជាគុណធម៌ដ៏ខ្ពង់ខ្ពស់ តាមរយៈចំណេះដឹង យើងអាចដឹងនូវការសប្បាយរីករាយណាមួយត្រូវស្វែងរក ណាមួយត្រូវចៀសវាង។
- លោកពោលថា នៅក្នុងលោកយើងនេះ ដាច់ខាត គ្មាននរណាម្នាក់អាចសប្បាយពេញលេញបានទេ ប្រសិនបើពួកគេមិនរស់នៅជីវិតប្រកបដោយគុណធម៌។ បើមិនមែនគុណធម៌នៅក្នុងខ្លួនវាទេ វានាំឱ្យផលវិបាកនៃការសប្បាយ និងមានការឈឺចាប់ភ័យខ្លាច។



## L'Épicurism (341-270BC)

- អំពីច្បាប់ធម្មជាតិ លោកថា អាចនិយាយពីបញ្ហានេះបានតែក្នុងករណីសង្គមមនុស្សជំនាន់ដើម ដែលមានរបៀបរស់នៅស្រដៀង ទៅនឹងហ្វូងសត្វ ហើយពុំទាន់មានការអនុម័តច្បាប់នៅឡើយ។
- សីលវិជ្ជា ជាសម្ព័ន្ធចំណងរវាងគំនិតអំពីរូបធាតុ និងគំនិតអំពីនយោបាយ-ច្បាប់។ តម្លៃចម្បងនៃសីលធម៌របស់អេពីគួរ ស្រោបទៅដោយលក្ខណៈបុគ្គល(Individual character) ដូចជាភាពរីករាយសេរីភាព។

## L’Épicurism (341-270BC)

- ដើម្បីកុំឱ្យប៉ះពាល់ធ្ងន់ធ្ងរពេកដល់អ្នកដែលមានជំនឿទៅលើអត្ថិភាពនៃ ព្រះ ដែលគេយល់ថាជាអ្នកបង្កើតលោក និងជាអ្នកដែលធ្វើអន្តរាគមន៍ជួយសង្គ្រោះ ឬដាក់ទោសមនុស្ស អេពីគួរគ្រាន់តែនិយាយថា ព្រះ រស់នៅដោយសុខសាន្តនៅក្នុងអន្តរភព ហើយមិនរវល់នឹងសកម្មភាពរបស់មនុស្សទេ។
- ការស្វែងរកការសប្បាយ ពុំមានន័យថា ការត្រេកត្រអាលក្នុងកាមតណ្ហានោះឡើយ តែជាការលុបបំបាត់ទុក្ខព្រួយដែលគ្មានមូលដ្ឋានតែប៉ុណ្ណោះ។

## L'Épicurism (341-270BC)

- អេពីគួរ កើតឆ្នាំ៣៤១ មុនគ.ស នៅកោះ សាម៉ុស(Samos) ប៉ុន្តែគ្រួសាររបស់គាត់គឺ ជាអ្នកអាថែន។
- ឪពុកលោកជាគ្រូបង្រៀន។
- លោកមានសមត្ថភាពស្រាវជ្រាវទស្សនវិជ្ជា និងវិទ្យាសាស្ត្រ តាំងពីអាយុ១៤ឆ្នាំ។
- លោកបានធ្វើជាយោធានៅអាថែនក្នុងរយៈពេលមួយខ្លី។
- លុះអាយុបាន៣០ឆ្នាំ លោកបានក្លាយជាសាស្ត្រាចារ្យទស្សនវិជ្ជា ហើយបានបង្រៀនទស្សនវិជ្ជានៅទីក្រុង Mytilene ។

# L'Épicurism (341-270BC)

- អេពីគួរ បានចែកចំណង់ជាបីប្រភេទ៖
  1. ចំណង់ធម្មជាតិ និងចាំបាច់
  2. ចំណង់ធម្មជាតិ តែមិនចាំបាច់
  3. ចំណង់មិនធម្មជាតិ និងមិនចាំបាច់
- អេពីគួរ ទូន្មានឱ្យមនុស្សជ្រើសរើសយកការអនុវត្តតាមចំណង់ទី១សំខាន់ជាងគេបង្អស់ ក្នុងចំណោមចំណង់ទាំងបីនេះ។ លោកឱ្យជម្រុះចោលនូវចំណង់ទី៣ ពិព្រោះចំណង់ទី៣ វាជាកត្តាជំរុញឱ្យមានសេចក្តីទុក្ខព្រួយគ្រប់បែបយ៉ាង។
- ការសប្បាយរីករាយត្រូវបម្រើឱ្យវិចារណញ្ញាណ។

## L’Épicurism (341-270BC)

- គាត់បានបង្ហាត់បង្ហាញឱ្យឃើញថា សីលធម៌ ជាឧបករណ៍មួយដ៏មានកម្លាំងស័ក្តិសិទ្ធជាទីបំផុតដើម្បីស្វែងរកសុភមង្គលឱ្យជីវិត គឺពិព្រោះដោយហេតុថា គ្មានអ្វីដែលធ្វើឱ្យមនុស្សរស់បានសុខសប្បាយជាងការរស់នៅដោយទៀងត្រង់ នៅក្នុងសេចក្តីសុច្ចរិតយុត្តិធម៌នោះទេ, ដោយគ្មានអ្វីត្រូវបន្ទោសខ្លួនឯង, ដោយគ្មានបានប្រព្រឹត្តអកុសលកម្ម ឬឧក្រិដ្ឋកម្ម, ដោយគ្មានបានបំផ្លិចបំផ្លាញផលប្រយោជន៍របស់អ្នកដទៃ, ដោយធ្វើអំពើល្អឱ្យបានយ៉ាងច្រើនបំផុតដែលគេអាចធ្វើទៅបាន ហើយនៅចុងបញ្ចប់ដោយចៀសវាងកុំខកខានក្នុងការបំពេញករណីកិច្ចចំពោះជីវិត។



## L'Épicurism (341-270BC)

- អេពីគួរ ពន្យល់ថា គេត្រូវបំបាត់កង្វល់ទាំងឡាយដែលតែងតែមកញាំញីយើងគ្មានថ្ងៃចប់។ បើធ្វើដូច្នេះបាន គេអាចឈានទៅរកសេចក្ដីសុខដ៏ខ្ពង់ខ្ពស់បំផុត។
- អេពីគួរ តម្រូវឱ្យយើងប្ដូរលោកទស្សនៈ ជាបឋមគឺត្រូវយល់ការពិតឱ្យបានច្បាស់។
- អេពីគួរ យល់ថាប្រភពនៃកង្វល់ គឺសាសនា ដូចជាការខ្លាចចុះឋាននរក ជាដើម។ ដោយក្នុងគំនិតរបស់យើងមាន "ព្រះ" ជាអ្នកចាំតែដាក់ទោសយើងគ្រប់ជំហាន យើងតែងមានការភិតភ័យជាអចិន្ត្រៃយ៍។

# L’Épicurism (341-270BC)

- ជីវិតមួយខ្លីដែលគេបានប្រទះការសប្បាយ វាប្រសើរជាងជីវិតមួយវែងដែលគេប្រទះនឹងសេចក្តីធុញថប់។
- រឿងបន់ព្រះសំពះទេវតា រឿងអធិដ្ឋាន និងរឿងធ្វើពលីកម្មសក្ការៈបូជា, ជារឿងឥតប្រយោជន៍។ គ្មានបុណ្យអ្វីដែលត្រូវស្នើសុំពីព្រះ, គ្មានគួរអ្វីដែលគេត្រូវទៅលត់ជង្គង់ថ្វាយបង្គំនៅចំពោះពានទេវតា ឬអ្នកតា ទាក់ទងនឹងរឿងគ្រោះថ្នាក់ផ្សេងៗដែលធ្លាក់មកលើរូបយើងទាំងអស់គ្នានោះទេ។ ប៉ុន្តែ គេគួរតែសម្លឹងមើលអំពីបុព្វហេតុអស់ទាំងនេះដោយចិត្ត ស្ងប់ស្ងៀម ប្រាសចាកសេចក្តីរំភើបភ្ញាក់ផ្អើលក្នុងអារម្មណ៍វិញល្អជាង។

## L’Épicurism (341-270BC)

- ក្រោយមកគាត់បានបង្រៀននៅទីក្រុង Lampsacus ។ ការបង្រៀនទស្សនវិជ្ជានៅទីក្រុងទាំងពីរនេះ គាត់បានចំណាយពេលអស់៥ឆ្នាំ។
- ឆ្នាំ៣០៧ មុនគ.ស គាត់បានត្រឡប់មកទីក្រុងអាថែន វិញ។
- ឆ្នាំ៣០៦ មុនគ.ស អេពីគួរ បានបង្កើតសាលាទស្សនវិជ្ជាមួយ នៅក្នុងរបងផ្ទះរបស់ខ្លួន ដែលមានឈ្មោះថា សួនច្បារអេពីគួរ។
- លោកមករស់នៅអាថែនចាប់តាំងពីឆ្នាំនោះមករហូតដល់ពេលលោកទទួលមរណភាពនៅឆ្នាំ២៧០ មុនគ.ស។

## L'Épicurism (341-270BC)

- មនុស្សត្រូវចេះស្វែងរកសេចក្ដីសប្បាយ ព្រោះ ការសប្បាយជាគោលបំណងនៃជីវិត ជាការស្ដែងឡើងនូវសុភ មង្គល។ ការសប្បាយនោះគឺជាការសប្បាយតាមចំណង់ធម្មជាតិប៉ុន្តែត្រូវជ្រើសរើសយកការសប្បាយណាដែលចាំបាច់។
- សេចក្ដីរីករាយជាការចាប់ផ្ដើម និងជាការបញ្ចប់នៃជីវិតរុងរឿង។ សេចក្ដីសប្បាយរីករាយដូចអេពីគួរ មាន ន័យថា សេចក្ដីរីករាយ ដែលគ្មានការឈឺចាប់ខាងសម្ភារ: និង ស្មារតី។ ជាសេចក្ដីរីករាយ ដែលបានមកដោយអំពើសុចរិតត្រឹម ត្រូវ មិនមែនបានមកពីការឈឺចាប់របស់អ្នកដទៃ ឬបានមកពីការ លោភលន់សម្ភារ: និងអំណាចណាមួយ។

## L'Épicurism (341-270BC)

បំណងរួម។ បុគ្គលមិនអាចដកខ្លួនឱ្យចេញផុតពីផលប្រយោជន៍សង្គមបានឡើយ។

- លោកបញ្ជាក់ថា មនុស្សខ្លាចស្លាប់ មនុស្សខ្លាចអាទិទេពផង និងមនុស្សខ្លាចមនុស្សគ្នាឯងផង។ ទាំងនេះជាកង្វល់នៃសេចក្ដីទុក្ខព្រួយ។ ដើម្បីចៀសវាងផុតពីសេចក្ដីទុក្ខព្រួយនេះ មនុស្សត្រូវចុះកិច្ចសន្យាសង្គម ដោយមិនបង្ករវិនាសកម្មលើគ្នាទៅវិញទៅមក ។ ទស្សនៈកិច្ចសន្យាសង្គមនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើទស្សនៈរបស់លោក Jean Jacques Rousseau។



## L’Épicurism (341-270BC)

សេចក្តីស្លាប់ដែលមនុស្សភ័យខ្លាចបំផុតនោះ

គ្មានអ្វីចម្លែកទេ

ដរាបណាយើងនៅមានជីវិត

សេចក្តីស្លាប់មិននៅជាមួយយើងទេ

តែនៅពេលវាចូលមកដល់ យើងក៏មិនមានអត្ថិភាពដែរ។

## L'Épicurism (341-270BC)

- វាគ្មានរបស់អ្វីមួយដែលថាមិនកើតចេញពីរបស់អ្វីមួយទៀតនោះ ទេ ហើយអ្វីមួយដែលមានរូបរាងឡើង រួចហើយក៏មិនអាចរលត់ រលាយបាត់សូន្យសោះផងទាំងស្រុងទៅវិញដែរ។
- ការពិសោធន៍បានឱ្យយើងដឹងថា អង្គកាយអ្វីមួយតែងតែត្រូវបាន សាងសង់ឡើងដោយកម្ទេចនៃអង្គកាយផ្សេងៗដទៃទៀត។ ម្ល៉ោះ ហើយជាលទ្ធផលចុងបញ្ចប់ទៅ អង្គកាយនានាទាំងអស់តែងតែ មានប្រធានរួមជាមួយគ្នា...ដែលយើងច្រើនហៅថា វត្ថុធាតុដើម។
- អេពីគួរ យល់ថា វត្ថុធាតុដើមសុទ្ធសឹងតែជាអាតូម ឬកម្ទេចតូចៗ បំផុតដែលគេមិនអាចបំបែកបាន ហើយដែលអេពីគួរយល់ថាជា

ទ្រព្យសម្បត្តិច្រើនពុំផ្តល់ឱ្យយើងនូវភាពរីករាយ ច្រើនទេ ពិព្រោះវាផ្តល់ទុក្ខទោសដល់យើងនៅ ពេលយើងបាត់បង់វា។

## L'Épicurism (341-270BC)

- យោងតាម អេពីគួរ ក្រុមអាតូមផ្សេងៗមិនមែនចេះតែអាចចូលទៅសាងសង់ក្នុងគ្រប់ប្រព័ន្ធអង្គកាយនៃវត្ថុធាតុនានានៅលើពិភពលោកនេះបានទេ។ ជាឧទាហរណ៍ តាមទំនងមើលទៅ ក្រុមអាតូមដែលបានសាងសង់អំបោះឡៀនមួយដុំ គឺមិនមែនក្រុមអាតូមដែលបានសាងសង់ត្បូងពេជ្រនោះទេ។
- កម្ទេចតូចៗនៃអង្គកាយទាំងនេះ បានស្ថិតនៅក្នុងសភាពនៃចលនាជាអចិន្ត្រៃយ៍។ គឺហេតុដូច្នោះហើយ បានជាគ្មានរបស់អ្វីមួយនៅក្នុងធម្មជាតិដែលស្ថិតនៅក្នុងសភាពដដែលទាល់តែសោះ។ វត្ថុខ្លះក៏មានការស្រុតចុះអន់ថយ ចំណែកវត្ថុខ្លះទៀតក៏

## L’Épicurism (341-270BC)

កើនទំហំឡើង ដោយសារវាបានទទួលកម្ទេចនៃវត្ថុធាតុដទៃដែលកំពុងចុះថយ។

- របស់ខ្លះចេះតែទទួលសភាពចាស់ជរា...ចំណែករបស់ខ្លះទៀតចេះតែបានទទួលកម្លាំងពលំថ្មីជារៀងរាល់ថ្ងៃ។
- នៅពេលដែលរបស់មួយកំពុងទទួលអាការៈពុករលួយពេញទំហឹង ក្រុមអាតូមដែលកំពុងតែរត់ចេញទៅក៏បានទៅរួបរួមជាមួយនឹងក្រុមអាតូមផ្សេងទៀត ដើម្បីសាងសង់ប្រព័ន្ធថ្មីមួយ ខុសប្លែកពីវត្ថុធាតុដែលកំពុងតែរលួយនោះ។

# L'Épicurism (341-270BC)

ក្នុងជីវភាពសង្គម និងនយោបាយ។

- អេពីគួរ បានអះអាងថា៖ ត្រូវតែរំដោះខ្លួនឱ្យចេញផុតពីកិច្ចការធម្មជាតិ និងកិច្ចការសង្គម។ តែលោកតម្រូវឱ្យមនុស្សរៀនសូត្រទស្សនវិជ្ជា ជាចាំបាច់ដោយចាត់ទុកថា ទស្សនវិជ្ជា ជាសុភមង្គលផ្នែកស្មារតី។
- គោលបំណងសំខាន់របស់អំណាចរដ្ឋ និងការបង្កើតចំណងនយោបាយឡើងគឺស្ថិតនៅត្រង់ថា ដើម្បីធានាបាននូវសុវត្ថិភាពរបស់មនុស្សក្នុងទំនាក់ទំនងសង្គម ធ្វើឱ្យចំណងស្មារតីរបស់ពួកគេមានភាពប្រសើរជាង ពិសេស មិនបង្ករឱ្យពួកគេធ្វើនូវអ្វីៗ

# L’Épicurism (341-270BC)

- មនុស្សត្រូវជម្នះនូវសេចក្តីតក់ស្លុតពីរគឺ ខ្លាចអាទិទេព និងខ្លាចស្លាប់។ សេចក្តីតក់ស្លុតទាំងពីរនេះ ជាបុព្វហេតុនៃកង្វល់នៃសេចក្តីទុកព្រួយ។ ព្រោះនៅពេលដែលមានសេចក្តីទុក្ខព្រួយ មនុស្សមិនអាចរកសុភមង្គលឱ្យខ្លួនឯងបានឡើយ។ ដើម្បីចៀសផុតពីសេចក្តីទុក្ខព្រួយ មនុស្សត្រូវមានកិច្ចសន្យាមិនត្រូវបង្កវិនាសកម្មដល់អ្នកដទៃ និងសង្គមឡើយ។



# L’Épicurism (341-270BC)

- មនុស្សម្នាក់ៗចេះតែនឹកស្មានស្រមៃ ឬ មានគោលប្រាថ្នាថាគេនឹងបានរស់ក្សេមក្សាន្តទៅថ្ងៃមុខ, ក្នុងមួយរំពេចនោះ ក៏ស្រាប់តែសេចក្តីស្លាប់បានមកដល់...នៅចំពេលមួយដែលគេមិនទាន់បានសម្រេចគោលបំណងអ្វីទាំងអស់។
- គ្មានអ្វីដ៏ត្រឹមត្រូវ និងដ៏មានប្រយោជន៍ជាងការរស់នៅឱ្យបានសប្បាយ នៅក្នុងពេលបច្ចុប្បន្ននេះទេ។
- គេមិនត្រូវរាប់ពីសេចក្តីសុខនៃជីវិតមួយដោយសារតែគេមានអាយុវែងនៅលើផែនដីនេះទេ... គឺត្រូវរាប់តាមអាការៈសប្បាយ និងរសជាតិឆ្ងាញ់ពិសាដែលយើងបានភ្លក្សនោះវិញ។